# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៦៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែប្រែមាត្រា ៤នៃអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១០០/២១៣ ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០០ ស្តីពីការបញ្ចូលសមាសភាពឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- តាមសំណើរបស់ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

## ស ម្រ េ ច

### មាត្រា ១ .-

មាត្រា ៤នៃអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី ត្រូវបានកែប្រែដូចខាងក្រោម :



www.pheakdeylaw.com

មាត្រា ៤ ថ្មី : ក្រុមប្រឹក្សាគោលនយោបាយដីធ្លី មានសមាសភាពដូចតទៅ :

| | |
|---|---|
| - ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ប្រធាន |
| - អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ | អនុប្រធាន |
| - រដ្ឋមន្ត្រី នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| - រដ្ឋលេខាធិការ នៃក្រសួងអភិវឌ្ឍន៍ជនបទ | អនុប្រធាន |
| - រដ្ឋលេខាធិការ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិកអចិន្ត្រៃយ៍ |
| និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាគោលនយោបាយដីធ្លី | |
| - រដ្ឋលេខាធិការ នៃទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| - រដ្ឋលេខាធិការ នៃក្រសួងមហាផ្ទៃ | សមាជិក |
| - រដ្ឋលេខាធិការ នៃក្រសួងការពារជាតិ | សមាជិក |
| - រដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| - រដ្ឋលេខាធិការ នៃក្រសួងពាណិជ្ជកម្ម | សមាជិក |
| - រដ្ឋលេខាធិការ នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| - រដ្ឋលេខាធិការ នៃក្រសួងផែនការ | សមាជិក |
| - រដ្ឋលេខាធិការ នៃក្រសួងបរិស្ថាន | សមាជិក |
| - រដ្ឋលេខាធិការ នៃក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| - រដ្ឋលេខាធិការ នៃក្រសួងព័ត៌មាន | សមាជិក |
| - រដ្ឋលេខាធិការ នៃក្រសួង យុត្តិធម៌ | សមាជិក |
| - រដ្ឋលេខាធិការ នៃក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| - រដ្ឋលេខាធិការ នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| - រដ្ឋលេខាធិការ នៃក្រសួងទេសចរណ៍ | សមាជិក |
| - រដ្ឋលេខាធិការ នៃក្រសួងកិច្ចការនារី | សមាជិក |
| - ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | សមាជិក |
| - តំណាងក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | សមាជិក |
| - អគ្គលេខាធិការ គណៈកម្មការជាតិវិនិយោគកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |



www.pheakdeylaw.com

**មាត្រា ២ ..**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ ..**

រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន និងសមាជិកទាំងអស់នៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី ដូចមានសមាសភាពចែងក្នុងមាត្រា ១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៩ ខែ ១០ ឆ្នាំ ២០០៤ ·

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

ជ.ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

អនុប្រធានអចិន្ត្រៃយ៍

**សុខ អាន**

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គ្រប់ក្រសួង និងស្ថាប័ន
- ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- ដូចមាត្រា ៣
- ឯកសារ - កាលប្បវត្តិ

www.pheakdeylaw.com